ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៩ លេខ ០៥

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC



កសវ

Work Activities

ប្រចាំខែឧសភា ឆ្នាំ២០១៦



# មាតិកា

| ល.រ | បរិយាយ | លេខទំព័រ |
|---|---|---|

| I- | កិច្ចប្រជុំជំនាញបច្ចេកទេស | |
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា | ១-២ |
| II- | កិច្ចប្រជុំផ្ទៃក្នុងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ៣-៤ |
| III- | សកម្មភាពការងាររបស់ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត(ក្រុម RIA) | |
| ១- | ការវាយតម្លៃបឋមលើផលប៉ះពាល់នៃសេចក្តីព្រាងប្រកាសស្តីពី លក្ខខណ្ឌនៃការផ្តល់ កែសម្រួល ព្យួរ ដកហូត ឬបដិសេធអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ | ៥ |
| ២- | ការប្រជុំពិភាក្សារវាងក្រុម RIA នៃ ECOSOCC ជាមួយក្រុម RIA នៃក្រសួងការងារបណ្តុះបណ្តាល និងវិជ្ជាជីវៈលើសារៈប្រយោជន៍នៃការធ្វើការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តដែលបានអនុវត្តកន្លងមក | ៦ |
| ៣- | ការវាយតម្លៃបឋមលើផលប៉ះពាល់នៃប្រកាសស្តីពី ការគ្រប់គ្រងសំណល់ពីសេវាថែទាំសុខភាពក្នុងព្រះរាជាណាចក្រកម្ពុជា | ៧ |
| ៤- | ការវាយតម្លៃពេញលេញលើផលប៉ះពាល់នៃសេចក្តីព្រាងប្រកាសស្តីពី ការគ្រប់គ្រង និងការបង្កើតកសិដ្ឋានចិញ្ចឹមសត្វ | ៨ |
| IV- | សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១៦ | ៩-១១ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា

កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ផៃ សុខខេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា** ដោយមានការអញ្ជើញចូលរួមពី សមាជិក និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងអប់រំ យុវជន និងកីឡា។



ដោយមានការយកចិត្តទុកដាក់របស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ចំពោះវិស័យអប់រំ ជាពិសេសចំពោះកិច្ចខិតខំកំណែទម្រង់ ដើម្បីបុព្វហេតុធនធានមនុស្ស និងមូលធនមនុស្សសម្រាប់អភិវឌ្ឍប្រទេសជាតិ។ ឯកឧត្តមបណ្ឌិតសភាចារ្យ បានអនុញ្ញាតឲ្យក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឆ្លងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងកិច្ចប្រជុំជំនាញបច្ចេកទេសរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលមាន ECOSOCC និងក្រុមប្រឹក្សាអ្នកច្បាប់ ជាអ្នកដឹកនាំប្រជុំ។

អនុវត្តតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំច្បាប់ស្តីពីការអប់រំ ដែលត្រូវបានប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។ អនុវត្តតាមមាត្រា៧ នៃច្បាប់ស្តីពីការអប់រំ ដែលបានកំណត់ពីឋានានុក្រមរដ្ឋបាលនិងការគ្រប់គ្រងការអប់រំ និងក្របខណ្ឌយុទ្ធសាស្ត្រចតុកោណដំណាក់

កាលទី៣ របស់រាជរដ្ឋាភិបាលចំពោះវិស័យអប់រំ ក្នុងការរួមចំណែកអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពនិងគុណធម៌ សំដៅកសាងសង្គមកម្ពុជាឲ្យក្លាយជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន ក្រសួងបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា សំដៅកែសម្រួលរចនាសម្ព័ន្ធរបស់ខ្លួន ឲ្យឆ្លើយតបទៅនឹងកម្មវិធីកំណែទម្រង់វិស័យអប់រំ ដែលបានដាក់ចេញក្នុងនីតិកាលទី៥ នៃរដ្ឋសភានេះ។ ការកែសម្រួលរចនាសម្ព័ន្ធនេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងអនុវត្តកំណែទម្រង់នៃការអប់រំឲ្យកាន់តែមានប្រសិទ្ធភាព និងយកចិត្តទុកដាក់បណ្តុះបណ្តាលធនធានមនុស្សឲ្យក្លាយជាមូលធនមនុស្ស ដើម្បីសម្រេចចក្ខុវិស័យឆ្នាំ២០៣០ ដែលរាជរដ្ឋាភិបាលចង់ប្រែក្លាយប្រទេសកម្ពុជាជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ដែលប្រែក្លាយជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០ខាងមុខ។

ក្រសួងអប់រំ យុវជន និងកីឡា ពិសេស នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន និងនាយកដ្ឋានកាយវិទ្ធ និងសមាគមយុវជន។ ការបង្កើតនាយកដ្ឋានកិច្ចការប្រឡង គឺដើម្បីអនុវត្តមាត្រា២៦ នៃច្បាប់ស្តីពីការអប់រំឲ្យកាន់តែមានប្រសិទ្ធភាព និងជំរុញការអនុវត្តកំណែទម្រង់នៃការប្រឡងឲ្យកាន់តែមានលក្ខណៈវិជ្ជមានបន្ថែមទៀត។ ការបង្កើតនាយកដ្ឋានអប់រំពិសេស គឺដើម្បីជំរុញការអនុវត្តមាត្រា៣៨ នៃច្បាប់ស្តីពីការអប់រំ និងលើកកម្ពស់សមធម៌នៃការទទួលបានសេវាអប់រំឲ្យបានកាន់តែប្រសើរ ជាពិសេសសម្រាប់កុមារនិងជនពិការ និងជនជាតិដើមភាគតិច។ រីឯការបង្កើតនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន គឺដើម្បីលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងវិស័យអប់រំ ជាពិសេសស្របតាមការជំរុញនូវការអនុវត្ត E-government របស់រាជរដ្ឋាភិបាល។ ចំណែកការបង្កើតនាយកដ្ឋានកាយវិទ្ធនិងសមាគមយុវជន គឺស្របតាមការដែលរាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចជូនក្រសួងអប់រំ យុវជន និងកីឡា ទទួលខុសត្រូវលើការងារកាយវិទ្ធ។ នាយកដ្ឋានថ្មីទាំងបួននេះមានតួនាទីភារកិច្ចដូចបានកំណត់នៅក្នុងមាត្រា១០ មាត្រា២០ មាត្រា៣០ និងមាត្រា៣៨ នៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា។

សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា ចែកចេញជា ១៦ជំពូក ៥៨មាត្រា[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងនាពេលខាងមុខ៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុរបស់សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា។

# កិច្ចប្រជុំផ្ទៃក្នុងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៦ វេលាម៉ោង ១៥:០០ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) បានរៀបចំកិច្ចប្រជុំ ក្រោមអធិបតីភាពឯកឧត្តម **ខ៉ាន់ តិរុណា** អគ្គលេខាធិការ ECOSOCC ដើម្បីផ្សព្វផ្សាយអនុក្រឹត្យលេខ ៥៦ អនក្រ.បក ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យា ដោយមានការអញ្ជើញចូលរួមពី អគ្គលេខាធិការរង ប្រធានផ្នែក អនុប្រធានផ្នែក និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន ECOSOCC។ លទ្ធផលនិងខ្លឹមសារសំខាន់ៗនៃកិច្ចប្រជុំនេះមានដូចខាងក្រោម៖



១-ផ្សព្វផ្សាយអំពីយុទ្ធនាការថ្ងៃច័ន្ទពណ៌ខ្មៅដល់មន្ត្រី ដើម្បីឲ្យយល់ពីវិធានការអនុវត្តចំពោះជនទាំងឡាយណាដែលប្រព្រឹត្តយុទ្ធនាការថ្ងៃច័ន្ទពណ៌ខ្មៅ ដោយឈរលើមូលដ្ឋានច្បាប់ចំនួន០៤៖ ទី១-ច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី ទី២-ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ទី៣-ច្បាប់ស្តីពីសមាគមន៍និងអង្គការមិនមែនរដ្ឋាភិបាល និង ទី៤-ក្រមព្រហ្មទណ្ឌ ដើម្បីចៀសវាងការចាញ់បោកបញ្ឆោត និងមានការពាក់ព័ន្ធ។





២-ផ្សព្វផ្សាយអំពីអនុក្រឹត្យលេខ ៥៦ អនក្រ.បក ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាដល់មន្ត្រីក្នុងអគ្គលេខាធិការដ្ឋាន ECOSOCC ឲ្យបានជ្រាបជាព័ត៌មាន និងដើម្បីអនុវត្តចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦តទៅ។

៣-អង្គប្រជុំសម្រេចកំណត់ពេលវេលាបម្រើការងារដូចខាងក្រោម៖

-ពេលព្រឹក : ម៉ោងចូល ៨:០០ ម៉ោងចេញ ១២:០០

-ពេលរសៀល : ម៉ោងចូល ១៣:០០ ម៉ោងចេញ ១៧:០០

៤-កំណត់បទបញ្ជាផ្ទៃក្នុង ដើម្បីជំរុញការងារឲ្យកាន់តែមានប្រសិទ្ធភាពនាពេលខាងមុខ៕

# របាយការណ៍សង្ខេប
# ស្តីពីសកម្មភាពការងាររបស់ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត (ក្រុម RIA) ក្នុងការបណ្តុះបណ្តាលដល់ក្រុមវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្តិរបស់ក្រសួង

## ១-ការវាយតម្លៃបឋមលើផលប៉ះពាល់នៃសេចក្តីព្រាងប្រកាសស្តីពី លក្ខខណ្ឌនៃការផ្តល់ កែសម្រួល ព្យួរ ដកហូត ឬ បដិសេធអាជ្ញាប័ណ្ណប្រតិបត្តិការទូរគមនាគមន៍



កាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត (ក្រុម RIA) ប្រជុំបន្តជាមួយក្រុមវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (ក្រុម RIA) របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីពិភាក្សាពិនិត្យ និងផ្តល់យោបល់ លើការវាយតម្លៃបឋមលើផលប៉ះពាល់នៃសេចក្តីព្រាងប្រកាសស្តីពីលក្ខខណ្ឌនៃការផ្តល់ កែសម្រួល ព្យួរ ដកហូត ឬ បដិសេធអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍។

សេចក្តីព្រាងប្រកាសនេះមានគោលបំណងកំណត់នូវលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់កែសម្រួល ព្យួរ ដកហូត ឬ បដិសេធអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ និងមានវិសាលភាពអនុវត្តចំពោះប្រតិបត្តិការទូរគមនាគមន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។



ក្រុម RIA របស់ ECOSOCC បានពិនិត្យ និងយល់ឃើញថា ក្រុម RIA របស់ក្រសួង បានរៀបចំរបាយការណ៍RIA បានត្រឹមត្រូវតាមទម្រង់ និងការវិភាគក៏បានស៊ីជម្រៅផងដែរ។ ដោយបញ្ញត្តិនេះមានការប៉ះពាល់ដល់វិស័យឯកជន ដូច្នេះក្រុម RIA របស់ ECOSOCC បានស្នើក្រុម RIA របស់ក្រសួង ពន្លឿនការបញ្ចប់របាយការវាយតម្លៃបឋម ហើយបន្តទៅការវាយតម្លៃពេញលេញតែម្តង៕

២-ការប្រជុំពិភាក្សារវាងក្រុម RIA នៃ ECOSOCC ជាមួយក្រុម RIA នៃក្រសួងការងារបណ្តុះបណ្តាល និងវិជ្ជាជីវៈលើសារៈប្រយោជន៍នៃការធ្វើការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដែលបានអនុវត្តកន្លងមក



កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត( ក្រុម RIA ) ប្រជុំជាមួយក្រុមវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត( ក្រុម RIA ) របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីពិភាក្សាអំពីសារៈប្រយោជន៍នៃការធ្វើការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដែលក្រសួងបានអនុវត្តកន្លងមក៕



## ៣-ការវាយតម្លៃបឋមលើផលប៉ះពាល់នៃប្រកាសស្តីពី ការគ្រប់គ្រងសំណល់ពីសេវាថែទាំសុខភាពក្នុងព្រះរាជាណាចក្រកម្ពុជា

កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត (ក្រុម RIA) ប្រជុំបន្តជាមួយក្រុមវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (ក្រុម RIA) របស់ក្រសួងសុខាភិបាល ដើម្បីពិភាក្សាអំពីការវាយតម្លៃបឋមលើផលប៉ះពាល់នៃប្រកាសស្តីពី ការគ្រប់គ្រងសំណល់ពីសេវាថែទាំសុខភាពក្នុងព្រះរាជាណាចក្រកម្ពុជា។



គោលបំណងនៃប្រកាសនេះគឺរាល់ប្រភេទសំណល់ទាំងអស់ពីសេវាថែទាំសុខភាព តម្រូវការសម្រាប់កំណត់អត្តសញ្ញាណសំណល់ ការដាក់ស្លាកសញ្ញា និងចំណាត់ថ្នាក់ តម្រូវការបច្ចេកទេសសម្រាប់ការញែក ការប្រមូល ការរក្សាទុក ការលើកដាក់ ការដឹកជញ្ជូន ការសម្អាត និងការចោលនូវសំណល់ដែលកើតមានគ្រប់ទីតាំងសេវាថែទាំទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា។



កិច្ចប្រជុំពិភាក្សា និងផ្លាស់ប្តូរយោបល់ បានធ្វើដល់ធាតុទី២ក្នុងការធ្វើការវាយតម្លៃបឋមលើផលប៉ះពាល់ ស្តីអំពី "គោលបំណង" របស់ប្រកាស ហើយកិច្ចប្រជុំនេះគឺ ក្រុម RIA របស់ក្រសួងបានយកវិធីសាស្ត្រ RIA ធ្វើការវាយតម្លៃលើផលប៉ះពាល់ខាងលើ គ្រាន់តែជាការហាត់សាកល្បងប៉ុណ្ណោះ៕

## ៤-ការវាយតម្លៃពេញលេញលើផលប៉ះពាល់នៃសេចក្តីព្រាងប្រកាសស្តីពី ការគ្រប់គ្រងនិងការបង្កើតកសិដ្ឋានចិញ្ចឹមសត្វ

កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត (ក្រុម RIA) ប្រជុំជាមួយក្រុមវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (ក្រុម RIA) របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ស្តីពីការពិនិត្យចុងក្រោយនៃរបាយការវាយតម្លៃពេញលេញលើផលប៉ះពាល់សេចក្តីព្រាងប្រកាស ស្តីពីការគ្រប់គ្រងនិងការបង្កើតកសិដ្ឋានចិញ្ចឹមសត្វ" ។





ប្រកាសនេះមានគោលបំណងគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺឆ្លងសត្វ ការពារសុខភាពសត្វសុខភាពសាធារណៈ និងការការពារបរិស្ថាន។ ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះកសិដ្ឋានចិញ្ចឹមសត្វ (ប្រភេទ«ក» ខ្នាតធំ ប្រភេទ«ខ» ខ្នាតមធ្យម និងប្រភេទ «គ» ខ្នាតតូច)។

ក្រោយការប្រជុំពិនិត្យ និងពិភាក្សារួចមកអង្គប្រជុំបានសម្រេចថា ការវាយតម្លៃពេញលេញនេះ ត្រឹមត្រូវតាមទម្រង់នៃការវាយតម្លៃពេញលេញ និងមានខ្លឹមសារអត្ថន័យពេញលេញ អាចទទួលយកបាន៕

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៣/០៥/១៦ ម៉ោង០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្ដីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រចាំខែមីនា ឆ្នាំ២០១៦ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៣/០៥/១៦ ម៉ោង១៥:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការ "គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្ដីការនាយករដ្ឋមន្ត្រី។ |
| ៣ | ០៥/០៥/១៦ ម៉ោង០៩:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសម្ពោធជាផ្លូវការការិយាល័យទំនាក់ទំនងនៃមជ្ឈមណ្ឌលអាស៊ី នៃមូលនិធិជប៉ុនប្រចាំរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅស្ថានទូតជប៉ុន។ |
| ៤ | ០៥/០៥/១៦ ម៉ោង១៥:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ដើម្បីពិភាក្សាលើការងារអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៦/០៥/១៦ ម៉ោង០៧:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំបូកសរុបសកម្មភាពក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី-ខេត្ត ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលឆ្នាំ២០១៥ និងលើកទិសដៅការងារឆ្នាំ២០១៦ ក្នុងពិធីបិទ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងពិធីបើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្ដីការនាយករដ្ឋមន្ត្រី។ |
| ៦ | ០៩/០៥/១៦ ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ជាមួយនឹងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រុមហ៊ុន SCA និងក្រុមហ៊ុន EGIS ដើម្បីពិនិត្យលើការពង្រីកផ្លូវរត់ (Run Way) សម្រាប់អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
| --- | --- | --- |
| ៧ | ១០/០៥/១៦ ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិត វិទ្យាស្ថានវ៉ាន់ដា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ៨ | ១១/០៥/១៦ ម៉ោង១៦:៣០នាទី | ទទួលកិច្ចសម្ភាសន៍ទូរទស្សន៍ Tian Jin ស្តីពីកំណើនទេសចរណ៍នៃអាកាសយានដ្ឋានអន្តរជាតិ នៅក្នុងប្រទេសកម្ពុជា នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ១២/០៥/១៦ ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ជូនដល់និស្សិត សាកលវិទ្យាល័យអាយអាយស៊ី នៃបច្ចេកវិទ្យា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១០ | ១២/០៥/១៦ ម៉ោង១៦:៣០នាទី | ចូលរួមប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានគ្រប់ស្រុក ក្រុង ទូទាំងខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ នៅគេហដ្ឋាន ឯកឧត្តម បណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី។ |
| ១១ | ១៦/០៥/១៦ ម៉ោង០៩:៣០នាទី | ដឹកនាំកិច្ចប្រជុំដើម្បីពិភាក្សាធ្វើរបាយការណ៍របស់សាខាបក្សទី១៣ ជូនគណៈកម្មាធិការបក្សទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ១៦/០៥/១៦ ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ដើម្បីពិភាក្សាលើការរុះរើ និងសាងសង់ជាថ្មីនូវក្លោងទ្វារ "A" ច្រកចូលតំបន់ស្ថានីយ៍ភ្ញៀវពិសេស (VIP) នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | ១៨/០៥/១៦ ម៉ោង០៩:០០នាទី | អញ្ជើញចុះត្រួតពិនិត្យការស្តារស្រះរបស់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ឃុំព្រៃកប្បាស ឃុំក្តាញ់ និងឃុំតាំងយ៉ាប នៅស្រុកព្រៃកប្បាស ខេត្តតាកែវ។ |
| ១៤ | ២៥/០៥/១៦ ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ជូនដល់និស្សិត សាកលវិទ្យាល័យ អាស៊ីអឺរ៉ុប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៥ | **២៥/០៥/១៦**<br>**ម៉ោង១៥:៣០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើៈ<br>១-សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស។<br>២-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | **២៦/០៥/១៦**<br>**ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែមេសា ឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | **២៧/០៥/១៦**<br>**ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោមៈ<br>១-សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស។<br>២-បញ្ហាផ្សេងៗៈ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើៈ<br>២.១-ពិធីសារវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។<br>២.២-កិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាសរវាងរដ្ឋាភិបាលនៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន រួមទាំងពិធីសារចំនួន ០២។<br>២.៣-ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៧ និងទី៨ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៨ | **៣១/០៥/១៦**<br>**ម៉ោង០៨:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រចាំខែមេសា ឆ្នាំ២០១៦ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in